00898202

E276/2

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 10 / 04 / 2013
ម៉ោង (Time/Heure): 13:40
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

# អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១៣

**ជូន:** **ភាគីទាំងអស់ក្នុងសំណុំរឿង០០២**

**ពី:** **និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង**

**ចម្លងជូន:** **លោក/លោកស្រី ចៅក្រម និងមន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូង**

**កម្មវត្ថុ:** **ចម្លើយតបទៅនឹងសំណើតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុងរបស់សហព្រះរាជអាជ្ញា ជនជាប់ចោទ នួន ជា និង ខៀវ សំផន** (E236/4/1, E265, E271, E276, E276/1)

១. អង្គជំនុំជម្រះបានទទួលសំណើមួយចំនួនក្នុងការដាក់ភស្តុតាងថ្មីៗ នៅចំពោះមុខអង្គជំនុំជម្រះ ( ឯកសារ E236/4/1, E265, E271 និង E276)។

២. យោងតាមវិធាន៨៧(៤)នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះសាលាដំបូង អាចទទួលយកភស្តុតាងថ្មីៗដែលអង្គជំនុំជម្រះចាត់ទុកថា ផ្តល់សារប្រយោជន៍ដល់ការស្វែងរកការពិត តែភស្តុតាងនោះក៏ត្រូវបំពេញផងដែរនូវបទដ្ឋានជាភស្តុតាងបឋមនៃការពាក់ព័ន្ធ ភាពគួរឱ្យជឿជាក់បាន និងយថាភាពដែលតម្រូវដោយវិធាន៨៧(៣)ដែរ។ សម្រាប់ជាប្រយោជន៍នៃយុត្តិធម៌ នាពេលកន្លងមក អង្គជំនុំជម្រះបានចង្អុលបង្ហាញថា ឯកសារដែលពុំមានក្នុងបញ្ជីបឋមរបស់ភាគី តាមវិធាន៨០(៣) អាចទទួលយកជាភស្តុតាងថ្មីបាន តែឯកសារទាំងនោះត្រូវបំពេញតាមលក្ខខណ្ឌតម្រូវនៃវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង (ឯកសារE190, កថាខណ្ឌ១៩-២១)។ ជាចុងក្រោយភាគីត្រូវដាក់សំណើរួមគ្នាមួយស្រប

តាមវិធាន៨៧(៤)នៃវិធានផ្ទៃក្នុង សម្រាប់រាល់ឯកសារថ្មីៗដែលខ្លួនប៉ុនប៉ងប្រើប្រាស់ក្នុងអំឡុងពេលផ្តល់សក្ខីកម្មរបស់សាក្សី យ៉ាងយឺតបំផុតពីរសប្តាហ៍មុនវត្តមាននៃការផ្តល់សក្ខីកម្មរបស់សាក្សីនោះ (ឯកសារ E218, para. 22)។

៣. ជាធម្មតា ភាគីដាក់សំណើត្រូវគូសបញ្ជាក់ដល់អង្គជំនុំជម្រះថា ភស្តុតាងដែលដាក់ស្នើ គឺពុំទាន់មាននៅឡើយមុនពេលបើកការជំនុំជម្រះ ឬភស្តុតាងនោះនៅពុំទាន់រកឃើញនៅឡើយ បើទោះជាខ្លួនខិតខំព្យាយាមយ៉ាងណាក្តី។ យ៉ាងណាមិញ ក្នុងករណីជាក់លាក់ អង្គជំនុំជម្រះបានទទួលស្គាល់ភស្តុតាងដែលពុំបានបំពេញតាមលក្ខណវិនិច្ឆ័យនេះ ក្នុងនោះរួមមាន ភស្តុតាងដែលពាក់ព័ន្ធយ៉ាងខ្លាំងនឹងសម្ភារៈដែលបានដាក់រួចរាល់ហើយនៅចំពោះមុខអង្គជំនុំជម្រះ និងនៅពេលដែលផលប្រយោជន៍នៃយុត្តិធម៌តម្រូវឱ្យវាយតម្លៃរួមគ្នាលើប្រភពនៃភស្តុតាង។ ជាពិសេសនៅពេលដែលភស្តុតាងដាក់ស្នើនោះ គឺជាប្រភេទភស្តុតាងដោះបន្ទុក ហើយតម្រូវឱ្យមានការវាយតម្លៃដើម្បីជៀសវាងនូវភាពមិនត្រឹមត្រូវក្នុងការស្វែងរកយុត្តិធម៌ ឬនៅពេលដែលភាគីផ្សេងទៀតពុំបានជំទាស់ទៅនឹងភស្តុតាងនោះ (ឯកសារ E190 និង E172/24/5/1)។

៤. សហព្រះរាជអាជ្ញាស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះនូវលិខិតពីរច្បាប់ពីអគ្គលេខាធិការនៃអង្គការលើកលែងទោសអន្តរជាតិ (D84/2.3 និង D84/2.4) ("លិខិតអង្គការលើកលែងទោសអន្តរជាតិ")។ លិខិតទាំងនេះមាននៅក្នុងសំណុំរឿងតាំងពីថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០០៩ មកម្លេះ ប៉ុន្តែពុំត្រូវបានដាក់ក្នុងបញ្ជីបឋមរបស់សហព្រះរាជអាជ្ញា ស្របតាមវិធាន៨០(៣)នៃវិធានផ្ទៃក្នុង (ឯកសារ E265)។ ដោយសារតែមានបញ្ហាខាងការគ្រប់គ្រងឯកសារផ្ទៃក្នុង សហព្រះរាជអាជ្ញាបានរកឃើញភស្តុតាងដែលបានស្នើនៅពេលរៀបចំសវនាការលើឯកសារ នាថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១៣។ ដោយពុំមានការបកស្រាយពន្យល់បន្ថែម ការរកឃើញដ៏យឺតយ៉ាវក្នុងអំឡុងពេលរៀបចំសវនាការ គឺជិតបួនឆ្នាំបន្ទាប់ពីការដាក់សម្ភារៈនៅក្នុងសំណុំរឿង ដោយពុំបង្ហាញនូវការខិតខំប្រឹងប្រែងទាន់ពេលវេលា (*សូមមើល ឧ.* E251 កថាខណ្ឌ៣១)។ បន្ថែមលើនេះទៀត ក្រុមមេធាវីការពារក្តីជំទាស់នឹងការទទួលយកលិខិតរបស់អង្គការលើកលែងទោសអន្តរជាតិដែលអាចមានលក្ខណៈដាក់បន្ទុក និងច្រំដែលជាមួយនិងភស្តុតាងផ្សេងៗទៀតដែលបានដាក់រួចហើយនៅចំពោះមុខអង្គជំនុំជម្រះ (ឯកសារ E265/1)។ សហ-ព្រះរាជអាជ្ញាពុំបានបំពេញតាម ទាំងលក្ខខណ្ឌតម្រូវដ៏តឹងរ៉ឹងនៃវិធាន៨៧(៤)នៃវិធានផ្ទៃក្នុង និងពុំបាន

បង្ហាញអំពីកាលៈទេសៈពិសេស ដែលធានាដល់ការទទួលស្គាល់លិខិតរបស់អង្គការលើកលែងទោសអន្តរជាតិនោះទេ។ ដូច្នេះ សំណើនេះត្រូវបដិសេធចោល។

៥. ក្រុមមេធាវីការពារក្តីរបស់ នួន ជា ស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះនូវលិខិតពីសាក្សី TCW-110 និង TCW-326 (A71) ("លិខិត TCW-110")។ លិខិតនេះត្រូវបានដាក់ក្នុងសំណុំរឿងនៅថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០០៧ និងជាងប្រាំឆ្នាំក្រោយមក បានដាក់ស្នើមកអង្គជំនុំជម្រះនៅថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០១៣ (E236/4/1)។ ក្រុមមេធាវីការពារក្តី នួន ជា ពុំបានបង្ហាញថា ខ្លួនបានខិតខំប្រឹងប្រែងទាន់ពេលវេលាក្នុងការស្វែងរក និងស្នើសុំដាក់លិខិត TCW-110 នោះទេ។ យ៉ាងណាមិញ លិខិត TCW-110 ពាក់ព័ន្ធយ៉ាងជិតស្និទ្ធនឹងសក្ខីកម្មដែលនឹងត្រូវធ្វើដោយ TCW-110 ពិសេស ភាពដែលអាចជឿបាន និងបានបង្ហាញជាងពីរសប្តាហ៍មុនការផ្តល់សក្ខីកម្មរបស់សាក្សីរូបនេះ។ ហេតុដូច្នេះ អង្គជំនុំ-ជម្រះពិចារណាថា វាគឺជាប្រយោជន៍នៃយុត្តិធម៌ ដែលឯកសារនេះត្រូវតែវាយតម្លៃរួមគ្នានឹងសក្ខីកម្មរបស់សាក្សីនេះ។

៦. ក្រុមមេធាវីការពារក្តីរបស់ ខៀវ សំផន ស្នើសុំដាក់ក្នុងសំណុំរឿង និងដាក់នៅចំពោះមុខអង្គជំនុំជម្រះនូវបទសម្ភាសន៍មួយ ធ្វើឡើងដោយកាសែត *ភ្នំពេញប៉ុស្តិ៍* នាថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ២០១៣ ជាមួយលោក Philip SHORT ក្រោមចំណងជើងថា "អ្នកសរសេរជីវប្រវត្តិ ប៉ុល ពត និយាយអំពីតុលាការ" ("បទសម្ភាសន៍ជាមួយលោក SHORT")។ បទសម្ភាសន៍ជាមួយលោក SHORT ត្រូវបានស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះនៅថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៣ ពាក់ព័ន្ធនឹងសក្ខីកម្មដែលនឹងផ្តល់ដោយអ្នកជំនាញរូបនេះ (E271)។ អង្គជំនុំជម្រះពិចារណាថា ការបង្ហាញអំពីបទសម្ភាសន៍ជាមួយលោក SHORT ក្នុងរយៈពេល១៩ថ្ងៃ នៃការបោះពុម្ពផ្សាយឯកសារនេះ និងជាងមួយខែមុនការផ្តល់សក្ខីកម្មរបស់លោក Philip SHORT គឺជាការខិតខំប្រឹងប្រែងទាន់ពេលវេលា ។ បទសម្ភាសន៍នេះក៏ពាក់ព័ន្ធយ៉ាងជិតស្និទ្ធនឹងសក្ខីកម្មដែលអ្នកជំនាញរូបនេះនឹងផ្តល់សក្ខីកម្ម ហើយមានសារប្រយោជន៍ដល់ការស្វែងរកការពិត។ ហេតុដូច្នេះ លក្ខខណ្ឌតម្រូវនៃវិធាន៨៧(៤)នៃវិធាន ផ្ទៃក្នុងត្រូវបានបំពេញ។ យ៉ាងណាមិញ អង្គជំនុំជម្រះកត់សម្គាល់ថា បទសម្ភាសន៍ជាមួយលោក SHORT គឺមានតែជាភាសាអង់គ្លេស និងបារាំងប៉ុណ្ណោះ។ ការប្រើប្រាស់ និងការទទួលស្គាល់បទសម្ភាសន៍ជាមួយលោក SHORT ក្នុងការជំនុំជម្រះ គឺតម្រូវឱ្យមានជាភាសាខ្មែរឱ្យបានទាន់ពេលវេលាផងដែរ។

៧. ក្រុមមេធាវីការពារក្តីរបស់ ខៀវ សំផន ក៏បានស្នើសុំដាក់ក្នុងសំណុំរឿង និងដាក់នៅចំពោះមុខអង្គជំនុំជម្រះនូវបទសម្ភាសន៍ជាមួយអតីតព្រះមហាក្សត្រ នរោត្តម សីហនុ ដែលបានចូលទីវង្គត់ ("បទសម្ភាសន៍ជាមួយនរោត្តម សីហនុ") ដែលក្រុមមេធាវីការពារក្តីបានចោទប្រកាន់ថា មានលក្ខណៈផ្ទុយគ្នានឹងបទសម្ភាសន៍មួយទៀតជាមួយអតីតព្រះមហាក្សត្រដែលបានបង្ហាញដោយសហព្រះរាជ-អាជ្ញាក្នុងសវនាការលើឯកសារដែលបានប្រព្រឹត្តទៅនាថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១៣ (ឯកសារ E276)។ ក្រុមមេធាវីការពារក្តីរបស់ ខៀវ សំផន ពុំបានបង្ហាញថា ខ្លួនបានខិតខំប្រឹងប្រែងទាន់ពេលវេលាក្នុងការស្វែងរក និងបង្ហាញនូវបទសម្ភាសន៍ជាមួយព្រះមហាក្សត្រ នរោត្តម សីហនុ ទេ។ យ៉ាងណាមិញ បទសម្ភាសន៍ជាមួយព្រះមហាក្សត្រ នរោត្តម សីហនុ គឺមានលក្ខណៈជាភស្តុតាងដោះបន្ទុកដែលពាក់ព័ន្ធយ៉ាងជិតស្និទ្ធនឹងភស្តុតាងផ្សេងៗទៀត នៅចំពោះមុខអង្គជំនុំជម្រះ ហើយសហព្រះរាជអាជ្ញាក៏មិនបានជំទាស់ទៅនឹងការទទួលយកកិច្ចសម្ភាសន៍នោះដែរ (ឯកសារ E276/1)។ អង្គជំនុំជម្រះយល់ឃើញថា វាគឺជាប្រយោជន៍នៃយុត្តិធម៌ដែលភស្តុតាងនេះ ត្រូវតែវាយតម្លៃរួមគ្នានឹងភស្តុតាងផ្សេងៗទៀតដែលបានដាក់រួចរាល់ហើយនៅចំពោះមុខអង្គជំនុំជម្រះ។

៨. សរុបសេចក្តីមក អង្គជំនុំជម្រះពិចារណាឃើញថា លក្ខខណ្ឌតម្រូវនៃវិធាន៨៧(៤)នៃវិធានផ្ទៃក្នុង ត្រូវបានបំពេញទាក់ទិននឹងលិខិតរបស់ TCW-110, បទសម្ភាសន៍ជាមួយលោក SHORT និងបទសម្ភាសន៍ជាមួយអតីតព្រះមហាក្សត្រ នរោត្តម សីហនុ។ អង្គជំនុំជម្រះនឹងស្តាប់រាល់ការជំទាស់ទៅនឹងការទទួលស្គាល់ភស្តុតាងថ្មីនេះ អនុលោមតាមវិធាន៨៧(៣)នៃវិធានផ្ទៃក្នុង ប្រសិនបើ និងនៅពេលដែលក្រុមមេធាវីការពារក្តីស្នើសុំដាក់ភស្តុតាងនេះ នៅចំពោះមុខអង្គជំនុំជម្រះ។

៩. នេះជាការឆ្លើយតបជាផ្លូវការរបស់អង្គជំនុំជម្រះទៅនឹងឯកសារ E236/4/1, E265, E265/1, E271, E276 និងE276/1។